ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៣ លេខ ៩៥ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១៣

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

p

មាតិកា

I_ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះអស់លោក និងលោកស្រី ចំនួន ១៨ រូប ១០៧០៦

២២.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៧៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ស៊ូ យ៉ុងស៊ី (XU RONGXI) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន ១០៧០៨

២២.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ខនរ៉ាដ ស្វាហ្វស៍ (KONRAD SCHWARZ) ជនជាតិស្វីស សញ្ជាតិស្វីស កើតនៅ ទីក្រុងស៊ូរិក សហព័ន្ធស្វីស ១០៧០៩

២២.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះសប្បុរសជន ចំនួន ០២ រូប ១០៧១០

២២.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ២២ រូប ១០៧១១

២២.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ និងសប្បុរសជន ចំនួន ២៦ រូប ១០៧១៣

២២.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះព្រះសង្ឃ ឯកឧត្តម លោកជំទាវ ឧបាសក អស់លោក និងលោកស្រី ចំនួន ០៨ រូប ១០៧១៥

២២.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះលោក និងលោកស្រី ចំនួន ០២ រូប ១០៧១៦

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រីចំពោះឯកឧត្តម **Joachim Baron Von Marschall** ១០៧១៧

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៦ ស្តីពី ការកាត់ផ្ទៃដីទំហំ ២៩៤,៨៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱ្រាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ១០៧១៨

p

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៧ ស្ដីពី ការកាត់ផ្ទៃដីទំហំ ៥.៧៤ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ១០៧១៩

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៨ ស្ដីពី ការកាត់ផ្ទៃដីទំហំ ៤.៤៤ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ១០៧២០

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៨៩ ស្ដីពី ការតែងតាំង លោកស្រី ឈរ សៀកហ៊ួយ ជា ឧកញ៉ា ១០៧២១

២២-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩០ ស្ដីពី ការតែងតាំង ឯកឧត្ដម យូ ស៊ួយ៉ុង ជា ឧកញ៉ា ១០៧២២

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩១ ស្ដីពី ការកែសម្រួលសមាសភាពក្រុមប្រឹក្សា គណៈស្ថាបត្យករកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា ១០៧២៣

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩២ ស្ដីពី ការតែងតាំង ឯកឧត្ដម ឡុង សារពុទ្ធ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ទន្លេមេគង្គ មានឋានៈ ស្មើ អគ្គនាយក ១០៧២៦

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៣ ស្ដីពី ការតែងតាំងទីប្រឹក្សាអមទីស្ដីការ គណៈរដ្ឋមន្ត្រី ចំនួន ០២ រូប ១០៧២៧

២៣-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៤ ស្ដីពី ការតែងតាំង មន្ត្រីរាជការ ចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ១០៧២៨

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៤-១២-២០១៣-អនុក្រឹត្យលេខ ៥៥៩ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៨៨៦.៨៩ ហិកតា នៅស្រុក ថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីដីតម្រុយព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដី ឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩០ គ្រួសារ និងរក្សា ទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៧២៩

-អនុក្រឹត្យលេខ ៥៦០,៥៦១ អនក្រ.បក មិនទាន់បានទទួល

១១-១២-២០១៣-អនុក្រឹត្យលេខ ៥៦២ អនក្រ.បក ស្ដីពី ការកែសម្រួលអត្រាអាករពិសេសលើទំនិញ មួយចំនួន ១០៧៣៣

p

១៨-១២-២០១៣ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.បក ស្តីពី ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ នូវទីតាំងដីសម្រាប់ការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ១០៧៣៧
២០-១២-២០១៣ -អនុក្រឹត្យលេខ ៥៦៤ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ១០៧៤១
២០-១២-២០១៣ -អនុក្រឹត្យលេខ ៥៦៥ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ១០៧៤៩
១១-១២-២០១៣-អនុក្រឹត្យលេខ ១១៦៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៧៧០

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-១២-២០១៣ -សារាចរណែនាំលេខ ០០៤ សហវ. ស្តីពី ការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៣ ១០៧៩៨
០៧-១១-២០១៣-ប្រកាសលេខ ១១១៦ សហវ. ស្តីពី ការបង្វែរឥណទានជូនរាជធានីភ្នំពេញ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ ១០៨០១
០៨-១១-២០១៣-ប្រកាសលេខ ១១១៧ សហវ. ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៨០៦
០៨-១១-២០១៣-ប្រកាសលេខ ១១១៨ សហវ. ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៨០៨
០៨-១១-២០១៣-ប្រកាសលេខ ១១១៩ សហវ. ស្តីពី ការបង្វែរឥណទានជូនរដ្ឋបាលក្រុង ស្រុក នៃខេត្តកោះកុង សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ ១០៨១០

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៥-១១-២០១៣-ប្រកាសលេខ ៩២៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.អេ.អូ.អ៊ីមផត អិចផត ស៊ើវិស បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ១០៨១៤
១៥-១១-២០១៣-ប្រកាសលេខ ៩២៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ បង្កើតរោងចក្រផលិត ជ័រកៅស៊ូ ១០៨១៨
១៥-១១-២០១៣-ប្រកាសលេខ ៩២៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ១០៨២២

p

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១២៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ប្រោសព្រះរាជទាន

នូវ

ក/ គ្រឿងឥស្សរិយយស **សហមេត្រី** *ថ្នាក់* **ធិបឌិន្ទ** :

- *លោក* ZHOU YOU
- *លោក* HE SILI
- *លោកស្រី* MA ZHIYUN

ខ/ គ្រឿងឥស្សរិយយស **សហមេត្រី** *ថ្នាក់* **សេនា** :

- *លោក* QIU CHUANGXING
- *លោក* ZHANG FENGDONG
- *លោក* LIANG XINDA
- *លោក* ZOU GEN
- *លោក* WANG CAIWEN
- *លោក* HUANG SHUIGEN
- *លោក* LIU HUAXING
- *លោក* HUANG JIANJUN

ROYAUME DU CAMBODGE * LE MINISTRE ... ROYAL

-លោក XIN YUANXIN

-លោក XIN YUANLIANG

-លោក WANG KECHENG

-លោក DOU XIAOCHUN

-លោក SHENG HUI

-លោក YIN ZHI XIANG

គ/ គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** :

-លោក អ៊ុន ចំណាន

ព្រះមហាក្សត្រលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានដល់ ១៣១១.១២៥៤

លេខ: ១៣ ៦៣ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ .ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ី យ៉ុងស៊ី** (XU RONGXI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៥៧ នៅខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧រស.១៣១១.១២៩២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ១២៧៦ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ខនរ៉ាដ ស្វាហ្សស៍** (KONRAD SCHWARZ) ជនជាតិស្វីស សញ្ជាតិស្វីស កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧២ នៅទីក្រុងស៊ូរិក សហព័ន្ធស្វីស។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរាស. ១៣១១. ១២៩៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៥ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៨០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាង អភិវឌ្ឍន៍ប្រទេសជាតិ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

១- ឯកឧត្តមឧត្តមសេនីយ៍ឯក ហ្វូ ឫទ្ធី
២- ឯកឧត្តម ម៉ែន ទិបុល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ. ១៣១១.១២៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១២៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ដូច

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានីព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្នថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកជំទាវ ញ៉ែម សាខន ស ខេង ២-លោកជំទាវ នុត យ៉ឹន ស ចេង

៣-លោកជំទាវ យូ ឈឹម ៤-លោកស្រី ស៊ុច ចាន់ធូ

ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានីព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា :

១-លោកស្រី ស សិន ២-លោកស្រី ស ឈន់

៣-លោកជំទាវ ស ចេង

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឯកឧត្តម ពេជ្រ សុធិតា ២-លោកឧត្តមសេនីយ៍ត្រី ម៉ាន់ សាវឿន

៣-លោកវរសេនីយ៍ឯក ស៊ូ ម៉ារ៉ាឌី ៤-ឯកឧត្តម យ៉ឹម ខេង

៥-លោក ហួន ណារត

ROYAUME DU CAMBODGE • LE MINIST... ROYAL •
ព្រះបរមរាជវាំង

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោក ឌួន សុគន្ធា ២-លោក ជា សួរ

៣-លោកអនុសេនីយ៍ឯក លាង សារិទ្ធ

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-លោក ជិន សុខុម ២-លោក សេំ គឹមហេង

៣-លោកវរសេនីយ៍ត្រី ចំន ឆួច ៤-លោកអនុសេនីយ៍ឯក សំ សាម៉ុនី

ច-គ្រឿងឥស្សរិយយសស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

លោកអនុសេនីយ៍ត្រី សៀង សារ៉ែន

ឆ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

ឧបាសក សេំ ឈុន

ជ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោកឧត្តមសេនីយ៍ត្រី ហ្វាប ឋុន្នី ២-លោក ចំន ជា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.រកត.១១១៣.១២៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៤ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/ ១២៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់ព្រះរាជទាន

ចំពោះមន្ត្រីរាជការ និងសប្បុរសជន ចំនួន ២៦រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់ជាច្រើនក្នុងការបម្រើជាតិមាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក មួង ខាយ ២-លោក ញ៉ៅ លីយ៉ុង

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក អ៊ុង ខាន់ណារិទ្ធ ២-លោក អ៊ុកឧត្ត ឡុងទី

៣-លោក ថេង កន្តី

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១-លោក ហឿន ឡឿ ២-លោក អ៊ុក ឧត្តរិទ្ធ

៣-លោក កែវ សុផាន ៤-លោក អ៊ុង ភាណារ៉ែន

៥-លោក សុខ ចាន់ណាវុធ ៦-លោក ខាន់ ចាវសនា

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-លោក សួន ម៉ានិត ២-លោក អ៊ុក ជាវ៉ាន់ឌី

៣-លោក ឆុន សុភាព ៤-លោក ឈួយ ចណ្ណៈ

៥-លោក មឿន ចាន់លី ៦-វេជ្ជបណ្ឌិត អ៊ុយ គីណា

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-លោក លឹម សិរ៉ាចគ្រី ២-លោក ម៉ៅញ សាយ័ន្តសុម៉ាលី

៣-លោក មាស សន្តិភាព ៤-លោក ខួន ផាន់ណា

៥-លោក ហង្ស សុផាតតិរម្យ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា :

-លោក **គិត ចាន់ថន**

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១-លោក **សែន សំអឿន** ២-លោក **ម៉ា ម៉ាន់សារ៉ាត់**

៣-លោក **អ៊ុំ សំណាង**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នរស ១៣១១.១២៩៦

លេខ:១២៧៣ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ដល់

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-ព្រះតេជគុណនេតុបណ្ឌិតោ គៀន ម៉ិច
២-ឯកឧត្តម ម៉ុំ ភ្រាត
៣-លោកជំទាវ គីម ចាន់ សេង វិឡាក់
៤-លោកស្រី អ៊ុម ចំនួចន
៥-លោក ស្រ៊ី ថៃសេង
៦-ឧបាសក សៅរ៍ សាម៉ន
៧-ឧបាសិកា ភ្លាំ អាំងគីម
៨-លោកស្រី សោ ចាឈី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តរស.១៣១១.១២៩៧

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១២៧២ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ជូន

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍
លោក មាស នាយ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា
លោកស្រី ឆូង សុខពៅ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.រកត.១១១៣.១២៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១២៦៧ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម Joachim Baron Von Marschall

នូវ

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

៣រល ១៣១១.១២៩៩

លេខៈ១២៧១ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៣

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានកាត់ផ្ទៃដីទំហំ ២៩៨,៨៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ក្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព.រ.ស. ១៣១១.១៣០០

លេខ: ១២៧០ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៨៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានកាត់ផ្ទៃដីទំហំ ៥,៧៤ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ក្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល ១៣១១.១៣០១

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៦៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានកាត់ផ្ទៃដីទំហំ ៩,៩៩ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល. ១៣១១. ១៣០២

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១២៦៤ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា)

ត្រាស់បង្គាប់

តែងតាំង :

លោកស្រី ឈរ សៀកហ្វ៊ីយ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល ១៣១១.១៣០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៥៤ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា)

ត្រាស់បង្គាប់

តែងតាំង :

ឯកឧត្តម យូ ស៊ូយឿង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible].១៣១១.១៣០៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០១៣

លេខៈ ១២៨៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩១

ស្ដីពី

ការកែសម្រួលសមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិ ជាតិសាសនា រក្សាខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ ស្ដីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៥៨ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្ដីពីការកំណត់សមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា និងតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានកែសម្រួលសមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា :

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស

១- ឯកឧត្តម	អ៊ឹម ឈុនលឹម	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ប្រធាន
២- ឯកឧត្តម	ហង់ ជួនណារ៉ុន	រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
៣- លោកជំទាវ	ភឿង សកុណា	រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	អនុប្រធាន
៤- ឯកឧត្តម	ត្រាំ អ៊ីវតឹក	រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៥- ឯកឧត្តម	សំ បូរ៉ាត	ប្រធានគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក	អនុប្រធាន
៦- ឧកញ៉ា	គិត ម៉េង	ប្រធានសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
៧- ឧកញ៉ា	ពុង ឃាវសេ	ប្រធានសមាគមអ្នកសាងសង់កម្ពុជា	សមាជិក
៨- ឯកឧត្តម	ភឿង សុភ័ណ្ឌ	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន	សមាជិកអចិន្ត្រៃយ៍
៩- ឯកឧត្តម	អ៊ិត ប្រាំង	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១០-ឯកឧត្តម	សួស គង់	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១១-ឯកឧត្តម	ម៉ែន សុផល	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១២-ឯកឧត្តម	ប៉ាន សូរស័ក្តិ	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
១៣-ឯកឧត្តម	ឃឹន គិមស៊ាន	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
១៤-លោកជំទាវ	គង់ មញ្ញា	រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង	សមាជិក
១៥-ឯកឧត្តម	អ៊ឹន ទីរៈជាតិ	ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា	សមាជិក
១៦-ឯកឧត្តម	អុំ ម៉ុនធឿន	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
១៧-ឯកឧត្តម	ច័ន្ទ សំណាញ	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	សមាជិក
១៨-ឯកឧត្តម	ម៉ម សុផាណា	ទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១៩-ឯកឧត្តម	ឈី យុទ្រែ	សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	សមាជិក
២០-ឯកឧត្តម	ជេត ជាលី	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ	សមាជិក
២១-ឯកឧត្តម	ឌុច សុខត្ថិ	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	សមាជិក
២២-ឯកឧត្តម	អ៊ុម រម្យណី	នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា	សមាជិក
២៣-ឯកឧត្តម	អ៊ិច សេង	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យមេគង្គកម្ពុជា	សមាជិក
២៤-លោក	លឹម ទីរក្ស	ប្រធាននាយកដ្ឋានក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
២៥-លោក	ចាន់ សុឃាង	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យន័រតុន	សមាជិក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២៦-លោក **ឡៀង សីហា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបៀលប្រាយ សមាជិក

មាត្រា២: ត្រូវបានកែសម្រួលសមាសភាពអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា :

១-ឯកឧត្តម	**ភឿង សុភ័ណ្ឌ**	អគ្គលេខាធិការ	មានឋានៈស្មើរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម	**ហ៊ុយ ណារ៉ា**	អគ្គលេខាធិការរង	មានឋានៈស្មើរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៣-ឯកឧត្តម	**ឌី ស៊ីថា**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៤-ឯកឧត្តម	**ឆាយ ឬទ្ធិសែន**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៥-ឯកឧត្តម	**ញ៉ឹន ស៊ី**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៦-ឯកឧត្តម	**បេងហុង សុជាតិខេមរ៉ូ**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៧-ឯកឧត្តម	**ម៉េង ប៊ុណ្ណារិទ្ធ**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៨-ឯកឧត្តម	**ឡៅ និច្ចសីហា**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៩-ឯកឧត្តម	**ឌូស សារឿន**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
១០-ឯកឧត្តម	**អង់ កុសល**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា៣: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៤: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.១៣១១.១៣០៥

លេខៈ១២៧៩១ ស.ណ

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៣

សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម **ឡុង សារាវុធ** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៥.១៣១១.១៣០៦

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ១២៦៤ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៣

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន ០២រូប :

១.ឯកឧត្ដម **ជា សុខុម** មានឋានៈស្មើ រដ្ឋមន្ត្រី
២.ឯកឧត្ដម **តូច សុផារ៉ា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣: សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរជ.១៣១១.១៣០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៧៩ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** ៖

១- ឯកឧត្តម **សោម សារុន**

២- ឯកឧត្តម **ចាន់ សាម៉ាត**

៣- ឯកឧត្តម **សុខ សុគា**

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការៈ ១៣១១.១៣០៨

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១២៥៣ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៥៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៨៨៦,៨៩ ហិកតា នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩០ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៥៨២ ខបជ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១: ត្រូវបានកាត់ផ្ទៃដីទំហំ ៨៨៦,៨៩ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៨៦៧,៤៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៩,៤០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ផ្លូវ, ប្រឡាយ, អូរ...) នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្ម ជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ១៩០ គ្រួសារ នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

មាត្រា ៣: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

មាត្រា ៤: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

p

មាត្រា ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៨ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៥៣ អនក.បក ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ៤៤៦,៨៩ ហិកតា នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីដីតំបន់ព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩០ គ្រួសារ និងទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦២ - អនក្រ - បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលអត្រាអាករពិសេសលើទំនិញមួយចំនួន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- [illegible]ព្រះរាជក្រមលេខ ០១. នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១.នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន

- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ២២៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១.-

ត្រូវបានតម្លើងអត្រាអាករពិសេសពី ២០% ទៅ ៣០% លើមុខទំនិញចំនួន ១៣៣ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ ៨៧០១.២០.១០ ៨៧០១.២០.៩០

៨៧០២.១០.១០	៨៧០២.១០.៤១	៨៧០២.១០.៤៩	៨៧០២.១០.៥០	៨៧០២.១០.៦០
៨៧០២.១០.៧១	៨៧០២.១០.៧៩	៨៧០២.១០.៨១	៨៧០២.១០.៨៩	៨៧០២.១០.៩០
៨៧០២.៩០.១២	៨៧០២.៩០.១៣	៨៧០២.៩០.១៤	៨៧០២.៩០.១៩	៨៧០២.៩០.៩២
៨៧០២.៩០.៩៣	៨៧០២.៩០.៩៤	៨៧០២.៩០.៩៥	៨៧០២.៩០.៩៩	៨៧០៤.១០.១៣
៨៧០៤.១០.១៤	៨៧០៤.១០.១៥	៨៧០៤.១០.១៦	៨៧០៤.១០.១៧	៨៧០៤.១០.១៨
៨៧០៤.១០.២៣	៨៧០៤.១០.២៤	៨៧០៤.១០.២៥	៨៧០៤.១០.២៦	៨៧០៤.១០.២៧
៨៧០៤.១០.២៨	៨៧០៤.២១.១១	៨៧០៤.២១.១៩	៨៧០៤.២១.២១	៨៧០៤.២១.២៣
៨៧០៤.២១.២៤	៨៧០៤.២១.២៥	៨៧០៤.២១.២៩	៨៧០៤.២២.១១	៨៧០៤.២២.១៩
៨៧០៤.២២.២១	៨៧០៤.២២.២៣	៨៧០៤.២២.២៤	៨៧០៤.២២.២៥	៨៧០៤.២២.២៩
៨៧០៤.២២.៣១	៨៧០៤.២២.៣៩	៨៧០៤.២២.៤១	៨៧០៤.២២.៤៣	៨៧០៤.២២.៤៤
៨៧០៤.២២.៤៥	៨៧០៤.២២.៥១	៨៧០៤.២២.៥៩	៨៧០៤.២៣.១១	៨៧០៤.២៣.១៩
៨៧០៤.២៣.២១	៨៧០៤.២៣.២៣	៨៧០៤.២៣.២៤	៨៧០៤.២៣.២៥	៨៧០៤.២៣.២៩
៨៧០៤.២៣.៥១	៨៧០៤.២៣.៥៩	៨៧០៤.២៣.៦១	៨៧០៤.២៣.៦៣	៨៧០៤.២៣.៦៤
៨៧០៤.២៣.៦៥	៨៧០៤.២៣.៦៦	៨៧០៤.២៣.៦៩	៨៧០៤.២៣.៧១	៨៧០៤.២៣.៧៩
៨៧០៤.២៣.៨១	៨៧០៤.២៣.៨៣	៨៧០៤.២៣.៨៤	៨៧០៤.២៣.៨៥	៨៧០៤.២៣.៨៦
៨៧០៤.២៣.៨៩	៨៧០៤.៣១.១១	៨៧០៤.៣១.១៩	៨៧០៤.៣១.២១	៨៧០៤.៣១.២៣
៨៧០៤.៣១.២៤	៨៧០៤.៣១.២៥	៨៧០៤.៣១.២៩	៨៧០៤.៣២.១១	៨៧០៤.៣២.១៩

p

៨៧០៤.៣២.២១ ៨៧០៤.៣២.២៣ ៨៧០៤.៣២.២៤ ៨៧០៤.៣២.២៥ ៨៧០៤.៣២.២៩ ៨៧០៤.៣២.៣១ ៨៧០៤.៣២.៣៩ ៨៧០៤.៣២.៤១ ៨៧០៤.៣២.៤៣ ៨៧០៤.៣២.៤៤ ៨៧០៤.៣២.៤៥ ៨៧០៤.៣២.៤៦ ៨៧០៤.៣២.៤៩ ៨៧០៤.៣២.៥១ ៨៧០៤.៣២.៥៩ ៨៧០៤.៣២.៦១ ៨៧០៤.៣២.៦៣ ៨៧០៤.៣២.៦៤ ៨៧០៤.៣២.៦៥ ៨៧០៤.៣២.៦៩ ៨៧០៤.៣២.៧២ ៨៧០៤.៣២.៧៩ ៨៧០៤.៣២.៨១ ៨៧០៤.៣២.៨៣ ៨៧០៤.៣២.៨៤ ៨៧០៤.៣២.៨៥ ៨៧០៤.៣២.៨៦ ៨៧០៤.៣២.៨៩ ៨៧០៤.៣២.៩១ ៨៧០៤.៣២.៩២ ៨៧០៤.៣២.៩៣ ៨៧០៤.៣២.៩៥ ៨៧០៤.៣២.៩៦ ៨៧០៤.៣២.៩៧ ៨៧០៤.៣២.៩៨ ៨៧០៤.៣២.៩៩ ៨៧០៤.៩០.១០ ៨៧០៤.៩០.៩១ ៨៧០៤.៩០.៩២ ៨៧០៤.៩០.៩៣ ៨៧០៤.៩០.៩៤ ៨៧០៤.៩០.៩៩ ៨៧០៥.១០.០០ ៨៧០៥.២០.០០ ៨៧០៥.៤០.០០ និង ៨៧០៥.៩០.៩០។

មាត្រា២.-

ត្រូវបានតម្លើងអត្រាអាករពិសេសពី ៤៥% ទៅ ៥០% លើមុខទំនិញចំនួន ៨០ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ៨៧០៣.១០.១០ ៨៧០៣.១០.៩០ ៨៧០៣.២២.១១ ៨៧០៣.២២.១៩ ៨៧០៣.២២.២១ ៨៧០៣.២២.២៩ ៨៧០៣.២២.៩២ ៨៧០៣.២២.៩៩ ៨៧០៣.២៣.៤០ ៨៧០៣.២៣.៥១ ៨៧០៣.២៣.៥២ ៨៧០៣.២៣.៥៣ ៨៧០៣.២៣.៥៤ ៨៧០៣.២៣.៦១ ៨៧០៣.២៣.៦២ ៨៧០៣.២៣.៦៣ ៨៧០៣.២៣.៦៤ ៨៧០៣.២៣.៧១ ៨៧០៣.២៣.៧២ ៨៧០៣.២៣.៧៣ ៨៧០៣.២៣.៧៤ ៨៧០៣.២៣.៩១ ៨៧០៣.២៣.៩២ ៨៧០៣.២៣.៩៣ ៨៧០៣.២៣.៩៤ ៨៧០៣.២៤.៤១ ៨៧០៣.២៤.៤៩ ៨៧០៣.២៤.៥១ ៨៧០៣.២៤.៥៩ ៨៧០៣.២៤.៧០ ៨៧០៣.២៤.៨១ ៨៧០៣.២៤.៨៩ ៨៧០៣.២៤.៩១ ៨៧០៣.២៤.៩៩ ៨៧០៣.៣១.១១ ៨៧០៣.៣១.១៩ ៨៧០៣.៣១.២០ ៨៧០៣.៣១.៤០ ៨៧០៣.៣១.៥០ ៨៧០៣.៣១.៨១ ៨៧០៣.៣១.៨៩ ៨៧០៣.៣១.៩១ ៨៧០៣.៣១.៩៩ ៨៧០៣.៣២.៤២ ៨៧០៣.៣២.៤៣ ៨៧០៣.៣២.៤៤ ៨៧០៣.៣២.៤៩ ៨៧០៣.៣២.៥២ ៨៧០៣.៣២.៥៣ ៨៧០៣.៣២.៥៤ ៨៧០៣.៣២.៥៩ ៨៧០៣.៣២.៦០ ៨៧០៣.៣២.៧១ ៨៧០៣.៣២.៧២ ៨៧០៣.៣២.៧៣ ៨៧០៣.៣២.៧៩ ៨៧០៣.៣២.៩២ ៨៧០៣.៣២.៩៣ ៨៧០៣.៣២.៩៤ ៨៧០៣.៣២.៩៩ ៨៧០៣.៣៣.៤៣ ៨៧០៣.៣៣.៤៤ ៨៧០៣.៣៣.៤៥ ៨៧០៣.៣៣.៤៩ ៨៧០៣.៣៣.៥៣ ៨៧០៣.៣៣.៥៤ ៨៧០៣.៣៣.៥៥ ៨៧០៣.៣៣.៥៩ ៨៧០៣.៣៣.៧០ ៨៧០៣.៣៣.៨១ ៨៧០៣.៣៣.៨៩ ៨៧០៣.៣៣.៩១ ៨៧០៣.៣៣.៩៩ ៨៧០៣.៩០.១២ ៨៧០៣.៩០.១៣ ៨៧០៣.៩០.១៩ ៨៧០៣.៩០.៥០ ៨៧០៣.៩០.៧០ ៨៧០៣.៩០.៨០ និង៨៧០៣.៩០.៩០។

មាត្រា៣.-

ត្រូវបានតម្លើងអត្រាអាករពិសេសពី ១៥% ទៅ២៥% លើមុខទំនិញចំនួន ១០ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ ៨៧០៣.២១.១០ ៨៧០៣.២១.២២ ៨៧០៣.២១.២៣ ៨៧០៣.២១.២៤ ៨៧០៣.២១.២៩ ៨៧០៣.២១.៣១ ៨៧០៣.២១.៣៩ ៨៧០៣.២១.៩១ ៨៧០៣.២១.៩២ និង ៨៧០៣.២១.៩៩។

មាត្រា៤.-

ត្រូវបានតម្លើងអត្រាអាករពិសេសពី ០% ទៅ ១០% លើមុខទំនិញចំនួន ០៣ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងលេខ៨៥១៧.១១.០០ ៨៥១៧.១២.០០និង៨៥១៧.១៨.០០។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

__ចម្លងជូន៖__

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ* **ហ៊ុន សែន** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*
- *គ្រប់សាលាខេត្តនិងសាលារាជធានី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ នូវទីតាំងដី សម្រាប់ការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានកំណត់បរិវេណដី សម្រាប់ធ្វើការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ដែលមានទីតាំងស្ថិតនៅភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

p

មាត្រា២.-

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុប ៩.៣០ ហិកតា ជាប្រភេទដីមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ដែលមានទីតាំងស្ថិតនៅភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥. មាត្រា ១៦. មាត្រា ១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ និងមាននិយាមការដូចខាងក្រោម៖

ID.	Northing	Easting
P1	1198435.27	601709.14
P2	1198442.53	601638.97
P3	1198449.79	601568.81
P4	1198457.06	601498.64
P5	1198513.88	601490.11
P6	1198570.71	601481.58
P7	1198627.53	601473.04
P8	1198684.36	601464.51
P9	1198695.94	601531.85
P10	1198707.53	601599.19
P11	1198719.11	601666.53

មាត្រា៣.-

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ឬការផ្ទេរកម្មសិទ្ធិ ការចេញបណ្ណ័សំគាល់សិទ្ធិកាន់កាប់នៃអចលនវត្ថុទាំងឡាយតាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលស្ថិតនៅក្នុងបរិវេណដីបង្អួកដូចបានពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតឱ្យសាងសង់សំណង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការផ្ទេរកម្មសិទ្ធិសម្រាប់បំរើផលប្រយោជន៍សាធារណៈ ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងទទួលទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ។

មាត្រា៤.-
			សរុបរួម	170.577.900	22.136.070	22.136.070	170.577.900

ប្រការ២: អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ
- រតនាគាររាជធានីភ្នំពេញ
  "ដើម្បីអនុវត្ត"
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:១១១៨...សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

ប្រកាស
ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៧៦អនក្រ.បក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ១០១៨សហវ.ប្រក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ ៣៤៩/១៣ មសខ.ពវ, ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ របស់មន្ទីរសុខាភិបាលខេត្តព្រៃវែង និង ចំណារបញ្ជូនលេខ ៦០៤ សន ចហ,ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០១៣ របស់ក្រសួងសុខាភិបាល

<u>សម្រេច</u>

ប្រការ១: ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់មន្ទីរសុខាភិបាលខេត្តព្រៃវែង នៃក្រសួងសុខាភិបាលសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកាដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតាពាន់រៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣	ឥណទានបច្ចុប្បន្ន	និយ័តកម្ម		ឥណទានថ្មីក្រោយនិយ័តកម្ម
						កើន	ថយ	
			សរុប			**436.530**	**436.530**	
			ការធ្វើនិយ័តកម្មជំពូក៦១			**107.635**	**107.635**	
61	615	6152	ការថែទាំ និង ការជួសជុលអគារ និងប្រាសាទ	1.985.000	1.985.000	-	107.635	1.877.365
61	615	6154	ការថែទាំបណ្តាញផ្សេងៗ	8.000	8.000	107.635	-	115.635
			ការធ្វើនិយ័តកម្មជំពូក៦៤			**328.895**	**328.895**	
64	642	6421	បៀវត្សមូលដ្ឋាន	4.865.900	4.865.900	-	328.895	4.537.005
64	642	6423	ប្រាក់បំណាច់ម៉ោងបន្ថែម	1.764.500	1.764.500	79.215	-	1.843.715
64	642	6427	ប្រាក់បំណាច់ទទួលខុសត្រូវ	1.002.900	1.002.900	247.680	-	1.250.580
64	645	6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ	89.100	89.100	2.000	-	91.100
			-កូនមានអាយុតិចជាង១៨ឆ្នាំ	48.000	48.000	-	-	48.000
			-កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ	5.100	5.100	2.000	-	7.100
			-ប្រាក់បំណាច់អ្នកក្នុងបន្ទុក	36.000	36.000	-	-	36.000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឯកឧត្តមអភិបាលខេត្តព្រៃវែង ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន_ព័ន្ធមុនីរ័ត្ន

<u>ចម្លងជូន</u>
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រៃវែង
- រតនាគារខេត្តព្រៃវែង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១១០៩...សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣

ប្រកាស
ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៧៦អនក្រ.បក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ១០១៨សហវ.ប្រក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមគណនីនិងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- លិខិតលេខ ១៧៥ សអយ.ខ , ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តសៀមរាប និងលិខិតលេខ ១៣៩១ ស.អ.យ, ចុះ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តសៀមរាប នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកាដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា:ពាន់រៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ឆ្នាំ២០១៣	ឥណទានបច្ចុប្បន្ន	និយ័តកម្ម		ឥណទានថ្មីក្រោយនិយ័តកម្ម
						កើន	ថយ	
			និយ័តកម្មផ្ទៃក្នុងជំពូក៦៥			210.000	210.000	
65	657	6574	ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ	-	-	210.000	-	210.000
65	658	6586	ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្មនីតិសម្បទានិងបណ្តុះបណ្តាលអភិវឌ្ឍន៍	580.000	580.000	-	210.000	370.000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តមអភិបាលខេត្តសៀមរាប ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន_ព័ន្ធមុនីរ័ត្ន

ចម្លងជូន

- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តសៀមរាប
- រតនាគារខេត្តសៀមរាប
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១១៩ សហវ.....

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣

ប្រកាស
ស្ដីពីការបង្វែរឥណទានជូនរដ្ឋបាលក្រុង ស្រុក នៃខេត្តកោះកុង សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្ដីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្ដីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦២៩ សហវ.ប្រក.ហម ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥ ២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៦៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីការបង្កើនបៀវត្ស មូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខ័ណ្ឌ ឃ ក្របខ័ណ្ឌគ ឋានន្តរស័ក្តិទី៣ និងក្របខ័ណ្ឌគ ឋានន្តរស័ក្តិទី២ ក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុង ស្រុក
- បានឃើញប្រកាសលេខ ២០៣ ប្រក សហវ.ថ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង
- បានឃើញសារាចរណែនាំលេខ ០០៨ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ២៨៥ សហវ.ហម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១០៤៧ សហវ.ហម ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១២ ស្តីពីការប្រគល់គាតព្វកិច្ចប្រមូលចំណូល និងការបែងចែកឥណទានចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញសេចក្តីជូនដំណឹងលេខ ០០៣ សហវ.ហម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ស្តីពីការអនុវត្តចំណាយថវិកាក្រុង ស្រុក សម្រាប់ឆ្នាំ២០១៣
- យោងសំណើលេខ ០៤៦ /១៣ បស ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកបុទុមសាគរ
- យោងសំណើលេខ ០៤៧ /១៣សគស ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកគិរីសាគរ
- យោងសំណើលេខ ០៣៦ សកក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកកោះកុង
- យោងសំណើលេខ ១២៥ /១៣ កខភម ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាក្រុងខេមរភូមិន្ទ
- យោងសំណើលេខ ០៣១ /១៣សម ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាស្រុកមណ្ឌលសីមា
- យោងសំណើលេខ ២៤៣ សប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកស្រែអំបិល
- យោងសំណើលេខ ០៣៦ /១៣សថប ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាស្រុកថ្មបាំង
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១: ត្រូវបានប្រតិបត្តិនៅក្នុងវង់ថវិការបស់រដ្ឋបាលក្រុង ស្រុក នៃខេត្តកោះកុង សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការបង្វែរឥណទានដូចមានក្នុងតារាងខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣	ឥណទានកែប្រែ		ឥណទានថ្មី
					កើន	ថយ	
១-ស្រុកបុទុមសាគរ							
62	624	6241	សោហ៊ុយដឹកជញ្ជូន	5,000	920		5,920
		6242	សោហ៊ុយបេសកកម្ម	2,000	616		2,616
		6243	សោហ៊ុយស្នាក់នៅ	8,000	4,417		12,417
64	641	6412	ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ	3,380		548	2,832
	642	6421	បៀវត្សមូលដ្ឋាន	76,190	1,103		77,293
		6422	ប្រាក់បំណាច់មុខងារ	6,530		268	6,262
	644	6441	បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ	1,920		240	1,680
	645	6454	ឧបត្ថម្ភនិវត្តជន		4,000		4,000
09			ចំណាយមិនបានគ្រោងទុក	10,000		10,000	
សរុប				113,020	11,056	11,056	113,020
២-ស្រុកគិរីសាគរ							
60	601	6011	សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ	400	300		700
	602	6021	សម្ភារៈការិយាល័យ និងបោះពុម្ព	4,700	700		5,400
	605	6052	សម្ភារឹម	2,000	500		2,500

	606	6061	អគ្គិសនី	4,500	500		5,000
		6062	ទឹក	1,000	500		1,500
62	622	6223	ប្រជុំ-សិក្ខាសាលា និងសន្និសីទ	1,000	500		1,500
		6224	សោហ៊ុយពិធីបុណ្យ	500	500		1,000
	624	6241	សោហ៊ុយដឹកជញ្ជូន	8,000	2,587		10,587
		6242	សោហ៊ុយបេសកកម្ម	2,000	700		2,700
		6243	សោហ៊ុយស្នាក់នៅ	7,000	1,000		8,000
	626	6262	សោហ៊ុយទូរគមនាគមន៍	500	213		713
64	641	6411	ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ	7,290		302	6,988
		6412	ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ	1,700	12		1,712
	644	6441	បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ	1,690	290		1,980
09			ចំណាយមិនបានគ្រោងទុក	8,000		8,000	
			សរុប	**50,280**	**8,302**	**8,302**	**50,280**
៣-ស្រុកកោះកុង							
64	641	6411	ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ	7,290	6		7,296
	642	6421	បៀវត្សមូលដ្ឋាន	70,800	4,143		74,943
		6422	ប្រាក់បំណាច់មុខងារ	4,750	1,935		6,685
		6424	ប្រាក់បំណាច់តំបន់	300	60		360
	644	6441	បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ		1,680		1,680
		6443	បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត	1,800	72		1,872
	645	6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ				
			កូនមានអាយុតិចជាង១៥ឆ្នាំ	500	50		550
			ប្រាក់បំណាច់អ្នកក្នុងបន្ទុក	500	54		554
		6452	មន្ត្រីមានផ្ទៃពោះ និងឧបត្ថម្ភកសម្រាលកូន	2,000	1,000		3,000
09			ចំណាយមិនបានគ្រោងទុក	9,000		9,000	
			សរុប	**96,940**	**9,000**	**9,000**	**96,940**
៤-ក្រុងខេមរភូមិន្ទ							
60	602	6021	សម្ភារៈការិយាល័យ និងបោះពុម្ព	10,000	1,500		11,500
62	624	6241	សោហ៊ុយដឹកជញ្ជូន	7,000	500		7,500
		6242	សោហ៊ុយបេសកកម្ម	1,000	660		1,660
		6243	សោហ៊ុយស្នាក់នៅ	4,000	2,000		6,000
64	642	6421	បៀវត្សមូលដ្ឋាន	130,400	5,866		136,266
	644	6442	លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ	78,500	340		78,840
	645	6453	មរណៈភាព		2,600		2,600
		6454	ឧបត្ថម្ភនិវត្តជន		2,534		2,534
09			ចំណាយមិនបានគ្រោងទុក	16,000		16,000	
			សរុប	**246,900**	**16,000**	**16,000**	**246,900**
៥-ស្រុកមណ្ឌលសីមា							
60	606	6062	ទឹក	900	500		1,400
62	624	6241	សោហ៊ុយដឹកជញ្ជូន	4,000	300		4,300
		6242	សោហ៊ុយបេសកកម្ម	1,000	500		1,500
		6243	សោហ៊ុយស្នាក់នៅ	4,000	568		4,568
64	641	6411	ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ	7,290	70		7,360
	642	6421	បៀវត្សមូលដ្ឋាន	95,100	5,062		100,162
	645	6454	ឧបត្ថម្ភនិវត្តជន	4,100	1,000		5,100

09			ចំណាយមិនបានគ្រោងទុក	8,000		8,000	
សរុប				124,390	8,000	8,000	124,390
៦-ស្រុកស្រែអំបិល							
60	601	6011	សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ	1,200	1,000		2,200
	602	6021	សម្ភារៈការិយាល័យ និងបោះពុម្ព	7,000	1,000		8,000
	606	6062	ទឹក	800	1,000		1,800
62	622	6223	ប្រជុំ-សិក្ខាសាលា និងសន្និសីទ	1,000	800		1,800
	624	6241	សោហ៊ុយដឹកជញ្ជូន	9,000	1,000		10,000
		6242	សោហ៊ុយបេសកកម្ម	2,000	1,000		3,000
		6243	សោហ៊ុយស្នាក់នៅ	13,000	2,000		15,000
64	642	6421	បៀវត្សមូលដ្ឋាន	89,100	4,419		93,519
		6422	ប្រាក់បំណាច់មុខងារ	7,990	800		8,790
	644	6443	បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត	3,800		1,900	1,900
	645	6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ				
			កូនមានអាយុតិចជាង១៥ឆ្នាំ	2,000		1,000	1,000
			ប្រាក់បំណាច់អ្នកក្នុងបន្ទុក	800		200	600
		6454	ឧបត្ថម្ភនិវត្តជន		2,081		2,081
09			ចំណាយមិនបានគ្រោងទុក	12,000		12,000	
សរុប				149,690	15,100	15,100	149,690
៧-ស្រុកថ្មបាំង							
62	628		សោហ៊ុយផ្សេងៗ		3,000		3,000
64	642	6421	បៀវត្សមូលដ្ឋាន	77,650	1,800		79,450
		6422	ប្រាក់បំណាច់មុខងារ	6,880	80		6,960
	645	6454	ឧបត្ថម្ភនិវត្តជន		2,636		2,636
65	652	6528	ចំណាយសង្គមផ្សេងៗ		1,484		1,484
09			ចំណាយមិនបានគ្រោងទុក	9,000		9,000	
សរុប				93,530	9,000	9,000	93,530
សរុបរួម				874,750	76,458	76,458	874,750

ប្រការ២: អភិបាលនៃគណៈអភិបាលស្រុកបុទុមសាគរ ស្រុកគិរីសាគរ ស្រុកកោះកុង ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកស្រែអំបិល និងស្រុកថ្មបាំងនៃខេត្តកោះកុងជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង
- រតនាគារខេត្តកោះកុង
  "ដើម្បីអនុវត្ត"
- ឯកសារ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : [illegible]

ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២៥១៨ ពណ.នគក ចុះថ្ងៃទី០៤.០៧.២០០៧ របស់ក្រសួងពាណិជ្ជកម្ម

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ី.អេ.អូ.អ៊ីមផត អិចផត សឺវីស ចុះថ្ងៃទី១៦.១០.២០១៣

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ី.អេ.អូ.អ៊ីមផត អិចផត សឺវីស (C.A.O IMPORT EXPORT SERVICE CO., LTD.) តំណាងដោយ លោក CASTRO FESTUS OSEMEKA សញ្ជាតិនីហ្សេរីយ៉ា អាយុ៤៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខA01525432 ចុះថ្ងៃទី២៥.០៨.២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ UMUDIKE Road. UMUDIKE. UKPOR NNEWI ANAMBRA State NIGERIA ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone . 855-23-211141 , Fax : 855-23-428263

ផ្លាកឈ្មោះរោងចក្រ៖ " *រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ី.អេ.អូ.អ៊ឹមផត អិចផត ស៊ើស* "

ទីតាំងរោងចក្រ៖ " *ផ្លូវហោរទ្រាយ ភូមិបឹងបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ* "

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។ ៗល៕

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

p

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣

ជ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រដ្ឋលេខាធិការ

ឡាយ ណាទីន

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: [handwritten]

ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ៤៣២៨/០៧ គ.វ.ក ចុះថ្ងៃទី១៩.១១.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ ចុះថ្ងៃទី១៩.០៩.២០១៣

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIAN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.) តំណាងដោយ លោក DUONG QUOC VIET សញ្ជាតិវៀតណាម អាយុ៦០ឆ្នាំ កាន់លិខិតឆ្លងដែនលេខB6589729 ចុះថ្ងៃទី០៧.០៥.២០១២ មានអាសយដ្ឋានបច្ចុប្បន្ន៖ 62 DO QUANG P. THAO DIEN Q2. TP CHM, VIETNAM. ធ្វើការបង្កើត រោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
ជ័រកៅស៊ូ	២២១៩

[initials]

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ . ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-2 : 428263

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកែច្នៃជ័រកៅស៊ូ តាន លៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ "*
ទីតាំងរោងចក្រ ៖ *" ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការគោរពការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

p

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ធំ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រដ្ឋលេខាធិការ

ឡាយ ណាទីន

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តកំពង់ធំ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : [illegible]

ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៣៤៣/១៣ គ.វ.ក ចុះថ្ងៃទី១៩.០២.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ចុះថ្ងៃទី ២៨.០៩.២០១៣

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GRAND TWINS INTERNATIONAL (CAMBODIA) PLC.) តំណាងដោយ លោក យ៉ាង សាវស៊ីន សញ្ជាតិខ្មែរ អាយុ៦០ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ010035849 ចុះថ្ងៃទី២៥.០៧.២០០១ មានអាសយដ្ឋានបច្ចុប្បន្នៈ កោះតៃវ៉ាន់ ប្រទេសចិន ធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោមៈ

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

ផ្លាកឈ្មោះរោងចក្រ ៖ " *រោងចក្រកាត់ដេរសម្លៀកបំពាក់ ហ្គោន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី* "

ទីតាំងរោងចក្រ ៖ " *ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ* "

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ ១២៨៨ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១៨.១២.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ និងវិញ្ញាបនបត្រលេខ ១១២ឧរថ.កឧ.បរ ចុះថ្ងៃទី១៨.១២.២០០៧ របស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រដ្ឋលេខាធិការ

ឡាយ ណាទីន

ចម្លងជូន:
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

p

បោះពុម្ពនៅអគ្គនាយកដ្ឋាន

រាជកិច្ច និង សេវាកុំព្យូទ័រ

នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី

p